៣-សេចក្តីសំរេចនេះធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៨ កាលសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសំរេចស្ថាពរផ្លូវការ ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ
ហត្ថលេខា និងត្រា
**ចាន់ សុក**

ជាការត្រឹមត្រូវតាមច្បាប់ដើម
អគ្គលេខាធិការ
**ម៉េង គឹមលី**

★★★

ភ្នំពេញ,ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៨

## សេចក្តីសំរេច លេខ ០៩ កបធ/សសរ

## ក្រុមប្រឹក្សាធម្មនុញ្ញ

***

-ការរំលឹកឃើញថា : ចាប់ពីថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត ពុំមានពាក្យបណ្តឹងតវ៉ាពីគណបក្សប៊ុនស៊ីនប៉ិចមកគណៈកម្មការរៀបចំការបោះឆ្នោត ខេត្តកំពង់ចាម អំពីការគំរាមកំហែងលោកម្ចាស់ ដោយហេតុថា អោយពាក់ផ្លាកសន្តិសុខដើរនៅមុខការិយាល័យបោះឆ្នោត នោះទេ ។

-ការរំលឹកឃើញថា : គ្មានបណ្តឹងភ្លាមៗ និងភស្តុតាងជាក់លាក់ ព្រមទាំងពុំអាចជឿជាក់ថា អោយម្នាក់ៗអាចឈរនៅមុខការិយាល័យបោះឆ្នោតគ្រប់ទីកន្លែងនៅថ្ងៃនោះដោយគ្មានគណបក្សដទៃដឹងឮនោះ ។

-ការរំលឹកឃើញថា : មានការទទួលស្គាល់លទ្ធផលសរុបនៃការបោះឆ្នោត ទូទាំងខេត្តកំពង់ចាម ដោយមានការចុះហត្ថលេខា នៃគណៈកម្មការរៀបចំការបោះឆ្នោត និងភ្នាក់ងារគណបក្សនយោបាយ ជាស្រេចរួចហើយ ។

-ការរំលឹកឃើញថា : ពាក្យបណ្តឹងនេះគ្មានទម្ងន់គ្រប់គ្រាន់ ដើម្បីបើកសវនាការ តាមមាត្រា១១៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គប្បីក្រុមប្រឹក្សាធម្មនុញ្ញ សំរេចបដិសេធ ពុំទទួលពាក្យបណ្តឹង តវ៉ានេះ ។

-ការរំលឹកឃើញថា : សេចក្តីសំរេចលេខ ០៨-១៦០៧/៩៨ គជប ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ ១៩៩៨ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវ ។

### សំរេច

១-បដិសេធពាក្យបណ្តឹងជំទាស់ លេខ ១៦២/៩៨ នគក របស់គណបក្សប៊ុនស៊ីនប៉ិច ចុះថ្ងៃ ទី១១ ខែ សីហា ឆ្នាំ ១៩៩៨ ដែលទាក់ទងនិងសេចក្តីសំរេច លេខ ០៨ - ១៦០៧/៩៨ គជប ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៨ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

២-តម្កល់សេចក្តីសំរេច លេខ ០៨-១៦០៧ /៩៨ គជប ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៨ របស់គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

៣-សេចក្ដីសម្រេចនេះធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៨ ក្នុងអង្គប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរពុំមានផ្លូវតវ៉ា ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ
ហត្ថលេខា និងត្រា
ចាន់ សុក

បានឃើញត្រឹមត្រូវតាមច្បាប់ដើម
អគ្គលេខាធិការ
ម៉េង គឹមលី

★★★

ភ្នំពេញ,ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៨

**សេចក្ដីសម្រេច លេខ ១០ កបធ/សសរ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

****

-បានឃើញថា : ក្រោយពីថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត ពុំមានពាក្យបណ្ដឹងតវ៉ាណាមួយ ជាផ្លូវការពីគណបក្សហ្វ៊ុនស៊ិនប៉ិចមកគណៈកម្មការរៀបចំការបោះឆ្នោត ខេត្តកំពង់ចាម អំពីការបន្លំសន្លឹកឆ្នោតទូទាំងស្រុក ១៦ នៃខេត្តកំពង់ចាម ។

-បានឃើញថា : តាមឯកសារស្ថិតិផ្លូវការ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ ១៩៩៨ របស់គណៈកម្មការរៀបចំការបោះឆ្នោត ខេត្តកំពង់ចាម ពុំឃើញមានចំនួនសន្លឹកឆ្នោត នៅក្នុងហិបឆ្នោត ដែលលើសពីចំនួនអ្នកបោះឆ្នោតចុះឈ្មោះ ។

-បានឃើញថា : មានការទទួលស្គាល់ពីលទ្ធផលរួមនៃការបោះឆ្នោត ទូទាំងខេត្តកំពង់ចាម ដោយមានការចុះហត្ថលេខា នៃគណៈកម្មការរៀបចំការបោះឆ្នោត និងភ្នាក់ងារគណបក្សនយោបាយ ជាច្រើនរួចហើយ ។

-បានឃើញថា : ពាក្យបណ្ដឹងនេះគ្មានបន្ទុកភស្តុតាងគ្រប់គ្រាន់ ដើម្បីបើកសវនាការ តាមមាត្រា១១៧ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គប្បីក្រុមប្រឹក្សាធម្មនុញ្ញ សម្រេចបដិសេធ ពុំទទួលពាក្យបណ្ដឹង តវ៉ានេះ ។

-បានឃើញថា : សេចក្ដីសម្រេចលេខ ០៨-១៦១៣/៩៨ គជប ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ ១៩៩៨ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវ ។

**សម្រេច**

១-បដិសេធពាក្យបណ្ដឹងជំទាស់ លេខ ១៦២/៩៨ អពក ចុះថ្ងៃ ទី១១ ខែ សីហា ឆ្នាំ ១៩៩៨ របស់គណបក្សហ្វ៊ុនស៊ិនប៉ិច ដែលទាក់ទងនឹងសេចក្ដីសម្រេច លេខ០៨-១៦១៣/៩៨ គជប ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

២-តម្កល់សេចក្ដីសម្រេច លេខ ០៨-១៦១៣/៩៨ គជប ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៨ របស់គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។